ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៤៣០

ចុះថ្ងៃទី ២១_០៦_២០០៥

សាលដីកា

លេខ : ៨៩ ខ

ចុះថ្ងៃទី ៣០_០៩_២០១០

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

..........

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣-០៩-២០១០ ដោយមានសមាសភាពដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក ម៉ែត សារ៉ាត់

**ក្រឡាបញ្ជី**

កញ្ញា លី ធិរតី

ដើម្បីជំនុំជម្រះលើបណ្តឹងទាស់នៃរឿងព្រហ្មទណ្ឌលេខ ៤៣០ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៥ ដែលមានៈ

១- ជនជាប់ចោទឈ្មោះ [redacted] ជាត ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរទល្មិត កើតនៅ [redacted] ទីលំនៅសព្វថ្ងៃក្នុង [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនជាប់ក្នុងពន្ធនាគារ ពីបទប្លន់។

២- ជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរទល្មិត កើតនៅ [redacted] ទីលំនៅសព្វថ្ងៃក្នុង [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនជាប់ក្នុងពន្ធនាគារ ពីបទប្លន់។

៣- ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ មុខរបរទល្មិត កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃក្នុង [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនជាប់ក្នុងពន្ធនាគារ ១៥ឆ្នាំ ពីបទប្លន់។

មានលោក កែ ចំរើន ជាមេធាវីការពារ។

៤- ជនជាប់ចោទឈ្មោះ [redacted] ម៉េត ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរទល្មិត កើតនៅ [redacted] ទីលំនៅសព្វថ្ងៃក្នុង [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ

[redacted](ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ទោសពីមុនជាប់ក្នុងពន្ធនាគារ ពីបទប្លន់។

<u>ត្រូវជាប់ចោទពីបទ:</u> ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅពន្ធនាគារខេត្តតាកែវ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៣ តាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

**៥- ជនជាប់ចោទឈ្មោះ** [redacted] ហ៊ុល ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរទណ្ឌិត កើតនៅ[redacted] ទីលំនៅសព្វថ្ងៃក្នុង[redacted] ឪពុកឈ្មោះ[redacted](ស) ម្តាយឈ្មោះ[redacted](ស) នៅលីវ ទោសពីមុនជាប់ក្នុងពន្ធនាគារ ពីបទប្លន់។

<u>ត្រូវជាប់ចោទពីបទ:</u> សមគំនិតក្នុងអំពើប៉ុនប៉ងធ្វើមនុស្សឃាត ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តតាកែវ កាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០០៣ តាមមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

១- ជនរងគ្រោះឈ្មោះ [redacted] សារិន ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរទណ្ឌិត និងជាមេកង ទីលំនៅសព្វថ្ងៃ ក្នុង[redacted]។

២- ជនរងគ្រោះឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ មុខរបរទណ្ឌិត និងជាប្រធានបន្ទប់ A ទីលំនៅសព្វថ្ងៃក្នុង[redacted]។

- តាមពាក្យបណ្តឹងទាស់លេខ ៨០ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត ប្តឹងទាស់មិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១០៥ (ខ) ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

<u>ដំណើររឿងមានដូចតទៅ:</u>

កាលពីយប់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៣ វេលាម៉ោង ១ និង ៣០នាទី ឈ្មោះ [redacted] ជាត ជាទណ្ឌិតក្នុងពន្ធនាគារខេត្តតាកែវ ដោយបានរៀបចំគំរោង បាននាំគូកនសម្លាប់ឈ្មោះ នាង សារិន និងឈ្មោះ [redacted] សុផល ប៉ុន្តែមិនបានសម្រេច ដោយមានអន្តរាគមពីមន្ត្រីពន្ធនាគារ បញ្ឈប់ទាន់ពេលវេលា ជនរងគ្រោះទាំងពីរនាក់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៩ (គ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ:

ក. ឈ្មោះ [redacted] ជាត ភេទប្រុស អាយុ ៣៣ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១៥ឆ្នាំ គិតពីថ្ងៃទទួលទណ្ឌកម្មក្នុងអំណាចសាលក្រមលេខ ០១ គ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០០៣ របស់តុលាការខេត្តតាកែវចប់សព្វគ្រប់។

ខ. ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ២១ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១៣ឆ្នាំ គិតពីថ្ងៃទទួលទណ្ឌកម្មក្នុងអំណាចសាលក្រមលេខ ១៥ ខ ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវចប់សព្វគ្រប់។

គ. ឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ ២៣ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១៣ឆ្នាំ គិតចាប់តាំងពីថ្ងៃទទួលទណ្ឌកម្មក្នុងអំណាចសាលក្រមលេខ ៤៤ គ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៣ របស់តុលាការខេត្តតាកែវចប់សព្វគ្រប់។

ឃ. ឈ្មោះ [redacted] សុន ភេទប្រុស អាយុ ២៣ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១៣ឆ្នាំ គិតពីថ្ងៃទទួលទណ្ឌកម្មក្នុងអំណាចសាលក្រមលេខ ៣៨ ខ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវចប់សព្វគ្រប់។

ង. ឈ្មោះ [redacted] ង៉ែត ភេទប្រុស អាយុ ៣៣ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១០ឆ្នាំ គិតចាប់តាំងពីថ្ងៃទទួលទណ្ឌកម្មតាមអំណាចសាលក្រមលេខ ១១ ខ ចុះថ្ងៃទី ២៦ ខែមិនា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវចប់សព្វគ្រប់។

ច. ឈ្មោះ [redacted] ណាត ភេទប្រុស អាយុ ២៤ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១៥ឆ្នាំ គិតចាប់តាំងពីថ្ងៃទទួលទណ្ឌកម្មក្នុងអំណាចសាលក្រមលេខ ១៧ ខ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៣ របស់តុលាការខេត្តតាកែវចប់សព្វគ្រប់។

ឆ. ឈ្មោះ [redacted] សុហឿន ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១០ឆ្នាំ គិតតាំងពីថ្ងៃចាប់ខ្លួន។

ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តតាកែវ កាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០០៣ តាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ជ. ឈ្មោះ [redacted] ហ៊ុល ភេទប្រុស អាយុ ២១ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១០ឆ្នាំ គិតចាប់តាំងពីថ្ងៃទទួលទណ្ឌកម្មក្នុងអំណាចសាលក្រមលេខ ០៩ ខ ចុះថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវចប់សព្វគ្រប់។

ពីបទ សមគំនិតក្នុងអំពើប៉ុនប៉ងធ្វើមនុស្សឃាត ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តតាកែវ កាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០០៣ តាមបញ្ញត្តិមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- បង្គាប់ឱ្យឈ្មោះ [redacted] ផាត, [redacted] ណាត, [redacted] ស៊ីណាត, [redacted] សុន, [redacted] ហ៊ុល សងជូសជុលការខូចខាត និងជម្ងឺចិត្តជាប្រាក់ក្នុងម្នាក់ៗ ១.០០០.០០០រៀល (មួយលានរៀល) សរុបទាំងអស់ចំនួន ៥.០០០.០០០រៀល (ប្រាំលានរៀល) ឱ្យទៅឈ្មោះ [redacted] សារិន ជាជនរងគ្រោះ ឯការទាមទារលើសពីនេះលើកចោល។

- បង្គាប់ឱ្យឈ្មោះ [redacted] សំណាង, [redacted] ង៉ែត, [redacted] សុហឿន សងជូសជុលការខូចខាត និងជម្ងឺចិត្តជាប្រាក់ក្នុងម្នាក់ៗ ចំនួន ១.០០០.០០០រៀល (មួយលានរៀល) សរុបទាំងអស់ចំនួន ៣.០០០.០០០រៀល (បីលានរៀល) ឱ្យទៅឈ្មោះ [redacted] សុផល ជាជនរងគ្រោះ ឯការទាមទារលើសពីនេះលើកចោល។

កាលបើរឹងទទឹងមិនព្រមបង់សងទេនោះ អនុញ្ញាតិឱ្យដាក់គុកបង្ខំលើរូបរាងកាយដើម្បីទាមទារធនទណ្ឌខាងលើ តាមបញ្ញត្តិមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយដើម្បីទាមទារធនទណ្ឌ។

៣- វត្ថុតាងមាន: អាវអ្នកទោសមួយ, កាំបិតតាំងតោមួយ, ដែកឆាបមួយ, ឈើពីរកំណាត់, ឡាំរីសមួយ, បន្ទាត់ប្រវែង ៤តឹកមួយ, លួសខ្សែភ្លើងមួយ សម្រេចរឹបអូស និងបំផ្លាញចោល។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី ០១ ខែមិនា ឆ្នាំ២០០៥ ចំពោះមុខជនល្មើស [redacted] ជាត, [redacted] ស៊ីណាត, [redacted] សុខ, [redacted] ហ៊ុល, [redacted] សំណាង, [redacted] ម៉ែត និងចំពោះមុខដើមបណ្តឹង [redacted] សារ៉ន និង [redacted] សុផល កំបាំងមុខ [redacted] ណាត និង [redacted] សុហឿន បើកផ្លូវប្តឹងទាស់ ១៥ថ្ងៃ និង ៦០ថ្ងៃទៀត សម្រាប់ប្តឹងឧទ្ធរណ៍ គិតចាប់ពីថ្ងៃទទួលដំណឹងពីសាលក្រមនេះ។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ១៨, ១៩, ២០, ២១ និង ២២ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ុល, [redacted] ស៊ីណាត , [redacted] ម៉ែត , [redacted] សំណាង និង [redacted] ជាត់ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩ (ត) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តតាកែវ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១០៥ (ខ) ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៨, ១៩, ២០, ២១ និង ២២ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ុល, [redacted] ស៊ីណាត, [redacted] ម៉ែត, [redacted] សំណាង និង [redacted] ជាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៩ (ត) ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ។

៤- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងទាស់លេខ ៨០ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត ប្តឹងទាស់មិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១០៥ (ខ) ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត បានឆ្លើយនៅសាលាដំបូងខេត្តតាកែវ។

ប្រធានក្រុមប្រឹក្សាអានចម្លើយជនរងគ្រោះឈ្មោះ [redacted] សារ៉ន និងជនរងគ្រោះឈ្មោះ [redacted] សុផល បានឆ្លើយនៅសាលាដំបូងខេត្តតាកែវ។

១៧៧

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

រឿងបណ្តឹងទាស់នេះអាចជម្រះទៅបានដោយមានមេធាវីការពារជនជាប់ចោទ។ រឿងនេះមានសាក្សីបញ្ជាក់ពីការប្រព្រឹត្តរបស់ជនជាប់ចោទ ដូច្នេះ មហាអយ្យការសាលាឧទ្ធរណ៍សូមសន្និដ្ឋានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០៥ (ខ) ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្នុងរឿងនេះការចោទប្រកាន់ គឺបទ ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា គឺអ្នកទោសបង្គរបួសស្នាមទៅលើអ្នកទោសគ្នាឯង ហើយនៅពេលកើតហេតុមានភាពងងឹត ហើយកូនក្តីខ្លួនបានឆ្លើយថា គាត់មិនបានប្រព្រឹត្តទេ ហើយម្យ៉ាងទៀតនៅពេលកើតហេតុកូនក្តីខ្លួននៅក្នុងបន្ទប់ទឹក ហើយព្រឹត្តការណ៍នោះកើតឡើងនៅក្រៅបន្ទប់ទឹក ដូច្នេះ សូមក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ឱ្យកូនក្តីខ្លួនផង។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១- បណ្តឹងទាស់លេខ ៨០ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ស៊ីណាត ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- កាលពីថ្ងៃទី 0៤ ខែមីនា ឆ្នាំ២០០៣ ទណ្ឌិតជាជនជាប់ចោទថា ទណ្ឌិតនៅអាគារ A នៃពន្ធនាគារខេត្តតាកែវ ចំនួន ៨នាក់ ក្នុងចំណោមនោះមានទណ្ឌិតជាជនជាប់ចោទឈ្មោះ [redacted] ស៊ីណាត ដែរ បានព្រួតគ្នាធ្វើសកម្មភាពប៉ុនប៉ងធ្វើឃាតទៅលើជនរងគ្រោះជាទណ្ឌិតឈ្មោះ [redacted] សារ៉ន និង [redacted] សុផល នៅក្នុងបន្ទប់ជាមួយគ្នា បណ្តាលឱ្យជនរងគ្រោះទាំងពីរនាក់ រងគ្រោះយ៉ាងធ្ងន់ធ្ងរ។

- នៅសវនាការសាលាឧទ្ធរណ៍នាពេលនេះជនជាប់ចោទពុំបាននាំយកមកនូវភស្តុតាងផ្សេងពីភស្តុតាង ដែលមានស្រាប់នៅក្នុងសំណុំរឿងតាំងតែពីសាលាដំបូងជូនសាលាឧទ្ធរណ៍ទេ។

៣- នៅក្នុងសាលដីកាព្រហ្មទណ្ឌលេខ ១០៥ "ខ" ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៩ សាលាឧទ្ធរណ៍បានលើកយកសំអាងហេតុមានភាពច្បាស់លាស់គ្រប់សព្វហើយ ហេតុនេះ សាលាឧទ្ធរណ៍មិនលើកសំអាងហេតុដដែលនេះឡើងវិញទៀតទេ។

៤- សាលដីកាព្រហ្មទណ្ឌលេខ ១០៥ "ខ" ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

១៧៨

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១- ទទួលបណ្ដឹងទាស់លេខ ៨០ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ស៊ីណាត ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០៥ "ខ" ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣- សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១០ កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ ចំពោះមុខមេធាវីការពារជនជាប់ចោទ ប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ ។

បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |
| [redacted] | [redacted] [redacted] | [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 13 ខែ ធ្នូ ឆ្នាំ ២០១០
ក្រឡាបញ្ជី
[redacted]

១៧៩